THE SCHOOL DISTRICT OF PHILADELPHIA

# យល់ដឹងអំពីវិធីសាស្ត្រ
# ការពិនិត្យឡើងវិញនូវផែនការរបស់សាលា



*ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា មានចក្ខុវិស័យច្បាស់លាស់មួយ៖ សម្រាប់ឱ្យក្មេងទាំងអស់មានលទ្ធភាពទៅរៀននៅសាលាមួយដែលល្អ នៅជិតកន្លែងដែលពួកគេរស់នៅ។*

គោលដៅរួមគឺ សម្រាប់ឱ្យក្រសួងរៀបចំសាលារៀននៅគ្រប់តំបន់រស់នៅទាំងអស់ ដើម្បីបំពេញតាមតម្រូវការនៃការអប់រំ ទៅតាមការផ្លាស់ប្តូរស្ថានភាពប្រជាជន ដោយ

- បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់អាគាររបស់យើង ដើម្បីធ្វើយ៉ាងណាឱ្យសិស្សអាចរៀននៅសាលាដែលមានគុណភាពខ្ពស់ ដែលនៅជិតកន្លែងពួកគេរស់នៅ
- ចំណាយប្រាក់លើអ្វីដែលជាសេចក្តីត្រូវការខ្លាំងបំផុត
- បង្កើតការផ្លាស់ប្តូរប្រកបដោយការគិតគូរយ៉ាងច្បាស់លាស់ សម្រាប់សិស្សថ្នាក់បឋមសិក្សា និង អនុវិទ្យាល័យ

ដើម្បីសម្រេចចក្ខុវិស័យនេះ យើងត្រូវគិតទុកជាមុន មិនមែនសម្រាប់តែអាគារសាលាថ្មីទេ គឺសម្រាប់ការកែលម្អអាគារដែលមានស្រាប់ផងដែរ។ ចាប់ផ្តើមនៅរដូវស្លឹកឈើជ្រុះឆ្នាំ ២០១៩ ក្រសួងនឹងសហការជាដៃគូជាមួយអ្នកជំនាញដើម្បីឱ្យពួកគេដឹកនាំការពិនិត្យឡើងវិញនូវផែនការរបស់សាលាជាច្រើនឆ្នាំ ដែលគេបានបង្កើតឡើងដើម្បីប្រើវិធីសាស្ត្រជាប្រព័ន្ធ ក្នុងការពិនិត្យមើលការប្រែប្រួលនៃស្ថានភាព ប្រជាជន និង សហគមន៍ នៅទូទាំងទីក្រុងរបស់យើង ដែលគេបានធ្វើការសន្និដ្ឋានទុកសម្រាប់ឆ្នាំខាងមុខៗ។

ការពិនិត្យឡើងវិញនេះ គេនឹងធ្វើឡើងជាបួនវេន ដែលវេននីមួយៗគេនឹងផ្តោតលើកន្លែងផ្សេងៗនៃទីក្រុង។ ព័ត៌មានដែលគេទទួលបានក្នុងវេននៃការពិនិត្យឡើងវិញនីមួយៗ នឹងត្រូវគេបញ្ចូលជាមួយ ការបង្ហាត់បង្រៀនរបស់សាលា និង ទិន្នន័យនៃគុណភាពអាគារ ដើម្បីធ្វើជាគោលគំនិតនៃការផ្តល់អនុសាសន៍ដល់ អគ្គនាយក និង គណៈកម្មការអប់រំ។

យើងដឹងថា ប្រធានបទ និង ដំណើរការនេះ នឹងមានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីគ្រប់តំបន់ទាំងអស់នៃទីក្រុងហ្វីឡាដែលហ្វ្យា។ ក្រសួងបានប្តេជ្ញាក្នុងការអភិវឌ្ឍន៍រួមគ្នា នៃជម្រើសដែលមានតុល្យភាពរវាងបំណងប្រាថ្នារបស់ សិស្ស និង ក្រុមគ្រួសារ នៅគ្រប់តំបន់សិក្សានីមួយៗ និង ការទទួលខុសត្រូវរួមរបស់ខ្លួន ដើម្បីធ្វើអ្វីៗដែលល្អបំផុតសម្រាប់អ្នកសិក្សាទាំងអស់។

## វិធីសាស្ត្រនៃការពិនិត្យឡើងវិញ

**ជំហានទី ១៖ សម្រេចអំពីវេន** (មិនា ២០១៩)
កំណត់តំបន់នៃទីក្រុង ដែលត្រូវបញ្ចូលក្នុងវេននៃដំណើរការត្រួតពិនិត្យនីមួយៗ

**ជំហានទី ២៖ ឱ្យអ្នកជំនាញចូលរួម** (រដូវក្តៅ ២០១៩)
ជួលក្រុមហ៊ុនដើម្បីនាំមកនូវការអនុវត្តន៍ដ៏ល្អបំផុត អ្នកជំនាញថ្នាក់ជាតិ និងគោលបំណងនៃដំណើរការត្រួតពិនិត្យឡើងវិញ

**ជំហានទី ៣៖ សម្រេចពីតំបន់សិក្សា**
ចែកសាលាជាតំបន់សិក្សាតូចៗ ដើម្បីផ្តល់ឱ្យក្រុមនីមួយៗនូវការយកចិត្តទុកដាក់ដែលចាំបាច់

**ជំហានទី ៤៖ បង្កើតគណៈកម្មការរៀបចំតំបន់សិក្សា (SAPC)**
បង្កើតក្រុមអ្នកសំខាន់ៗដែលមានការយល់ដឹងស៊ីជម្រៅពីសហគមន៍ និងជំនាញផ្នែកវិធីសាស្ត្រ ដើម្បីផ្តល់អនុសាសន៍ដល់ការអភិវឌ្ឍន៍

**ជំហានទី ៥៖ ធ្វើការសិក្សាគ្រប់ជ្រុងជ្រោយ**
បង្កើតរូបភាពនៃស្ថានភាពប្រជាពលរដ្ឋ នាពេលបច្ចុប្បន្ន និង នៅអនាគត នៃតំបន់សិក្សានីមួយៗ និង ផលប៉ះពាល់ដែលអាចកើតមានដល់សាលា

**ជំហានទី ៦៖ ចែកចាយលទ្ធផលនៃការសិក្សា**
ធ្វើយ៉ាងណាឱ្យសាធារណជនបានដឹងពី ទិន្នន័យ និង ការសិក្សា

**ជំហានទី ៧៖ ដឹងពីជម្រើស**
ចូលរួមជាមួយ SAPCs ដើម្បីពិចារណាពីជម្រើសដែលផ្អែកលើ លទ្ធផលនៃការសិក្សា និង តម្រូវការរបស់សហគមន៍

**ជំហានទី ៨៖ ឱ្យសគមន៍ចូលរួម**
ទទួលបានយោបល់ពីជម្រើស និង ផ្តល់ដំណឹងអំពីការកែប្រែ សម្រាប់ការពិចារណារបស់ SAPC

**ជំហានទី ៩៖ បង្កើតការផ្តល់យោបល់ចុងក្រោយ**
សម្រាប់ឱ្យគណៈកម្មការធ្វើការពិចារណា

**ជំហានទី ១០៖ ការអនុម័តរបស់គណៈកម្មការ**
ដោយការបោះឆ្នោតមតិភាគច្រើនរបស់គណៈកម្មការអប់រំ

**ជំហានទី ១១៖ ការអនុវត្តន៍**
ការផ្លាស់ប្តូរនឹងមានប្រសិទ្ធិភាពមិនឆាប់ជាងរដូវស្លឹកឈើជ្រុះនៃឆ្នាំបន្ទាប់

**ជំហានទី ៣-១១ នឹងធ្វើឡើងវិញសម្រាប់វេននីមួយៗនៃវិធីសាស្ត្រនៃការពិនិត្យឡើងវិញជាច្រើនឆ្នាំ**

*Khmer*